# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

## ការិយាល័យអគ្គនាយកនៃក្រសួងអប់រំ

**440 NORTH BROAD STREET, បន្ទប់លេខ ៣០១**
**PHILADELPHIA, PENNSYLVANIA 19130**

**WILLIAM R. HITE, JR., Ed.D.**
*អគ្គនាយកក្រសួងអប់រំ*

**ទូរស័ព្ទ៖ (២១៥) ៤០០-៤១០០**
**ទូរសារ៖ (២១៥) ៤០០-៤១០៤**

ថ្ងៃទី៦ ខែសីហា ឆ្នាំ២០១៥

ជូនចំពោះ សហគមន៍របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៖

ថ្ងៃនេះ ខ្ញុំបាទសរសេរលិខិតដើម្បីចែកជូនព័ត៌មានខ្លះៗ អំពីលទ្ធផលបឋមនៃការប្រឡង PSSA ថ្មី លើកទីមួយរបស់យើង ដែលបានផ្តល់ឲ្យសិស្សថ្នាក់ទី៣ ដល់ ថ្នាក់ទី៨ កាលពីឆ្នាំសិក្សាកន្លងទៅនេះ។ ការប្រឡងសម្រាប់ឆ្នាំ២០១៥ថ្មីនេះ ខុសគ្នាពីការប្រឡងដែលគេផ្តល់ឲ្យក្នុងឆ្នាំ២០១៤។ ការប្រឡងសម្រាប់ឆ្នាំ២០១៥ថ្មី គឺយោងទៅលើ មូលដ្ឋាននៃកម្មវិធីសិក្សារបស់រដ្ឋផិនស៊ីលវេញ៉ា (PA Core Standards) ដែលពិបាកជាងពីមុន ដែលជាចំណេះដឹង និងការប៉ិនប្រសប់ ដែលក្រុមប្រឹក្សាផ្នែកអប់រំរបស់រដ្ឋ បានកំណត់ថាជាអ្វីៗដែលសិស្សានុសិស្សរបស់រដ្ឋផិនស៊ីលវេញ៉ាត្រូវការ ដើម្បីត្រៀមខ្លួនសម្រាប់ មហាវិទ្យាល័យ និងអាជីព។

មិនគួរឲ្យភ្ញាក់ផ្អើលទេ -- ការផ្តល់នូវ ការប្រឡងទូទៅ និងការស្ទង់មើលចំណេះដឹង ដែលកាន់តែពិបាក -- លទ្ធផលបឋមបង្ហាញឲ្យឃើញថា សិស្សានុសិស្សមួយចំនួនតូចក្នុងរដ្ឋផែនស៊ីលវេញ៉ាបានពិន្ទុ ស្ទាត់ជំនាញ ឬ កម្រិតខ្ពស់ (proficient or advanced) ទាំងផ្នែក អក្សរសិល្ប៍អង់គ្លេស និង គណិតវិទ្យា ក្នុងការប្រឡង PSSAs ថ្មីនេះ។ លទ្ធផលនៃការប្រឡង PSSAs ថ្មីរបស់យើង ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរទូទាំងរដ្ឋ។

ក្នុងការពិនិត្យលទ្ធផលទាំងនេះ យើងត្រូវចាប់អារម្មណ៍ទៅលើចំណុចសំខាន់ៗមួយចំនួន៖

១. ការធ្លាក់ចុះនូវលទ្ធផលនៃការប្រឡង PSSAs ថ្មីរបស់សិស្ស **មិនមែន**បង្ហាញថាពួកគេមិនខិតខំសិក្សានោះទេ។ ការប្រឡងថ្មីនេះយោងទៅលើ វិញ្ញាសា និងចំណេះដឹង ដែលខុសគ្នា និងពិបាកជាងមុន ហើយមិនអាចយកមកប្រៀបធៀបជាមួយនិងលទ្ធផលនៃការប្រឡងពីមុនថា «ដូចគ្នាបានទេ»។ យើងដឹងថា សិស្សានុសិស្ស និងគ្រូ កំពុងប្រឹងប្រែងយ៉ាងខ្លាំង។ មានវិធីជាច្រើនដើម្បីស្ទង់មើល ចំណេះដឹង និងការប៉ិនប្រសប់ របស់សិស្សានុសិស្សរបស់យើង។ យើងដឹងថាសិស្សានុសិស្សរបស់យើងទាំងអស់ មានសមត្ថភាពអាចរីកលូតលាស់ផ្នែកការសិក្សា។

២. យើងខ្ញុំដឹងថា ការផ្លាស់ប្តូរដ៏សំខាន់នេះ ត្រូវចំណាយពេលដ៏យូរ ហើយតម្រូវឲ្យមានការចំណាយប្រាក់ដើម្បី ហ្វឹកហ្វឺនគ្រូ សម្ភារៈសិក្សា ការបង្រៀនសិស្សបន្ថែមក្រៅម៉ោងរៀន និងជំនួយផ្សេងៗទៀត។ យើងខ្ញុំកំពុងសម្របសម្រួល កម្មវិធីសិក្សា និងថវិការបស់យើង ឲ្យត្រូវតាមខ្នាតគំរូថ្មីដ៏ពិបាកនេះ។ លទ្ធផលកាលពីឆ្នាំទៅ គឺជាមូលដ្ឋានថ្មីដើម្បីចាប់ផ្តើម នៅពេលដែលយើងខិតខំធ្វើយ៉ាងណាដើម្បីឲ្យសិស្សានុសិស្សរបស់យើងទាំងអស់មានឱកាស និងត្រៀមខ្លួនជាស្រេចសម្រាប់ មហាវិទ្យាល័យ និង អាជីព។

៣. យើងមានគម្រោងការនឹងពិនិត្យឡើងវិញ ហើយនឹងធ្វើការកែសម្រួលអ្វីៗឲ្យត្រូវទៅតាមស្តង់ដានៃការទទួលសិស្សឲ្យចូលរៀន នៅវិទ្យាល័យរបស់យើង -- យើងបានរួមបញ្ចូលកត្តាផ្សេងៗជាច្រើន និងអ្វីៗដែលបានធ្វើជាយូរមកហើយ -- ដើម្បីធ្វើយ៉ាងណាកុំឲ្យការផ្លាស់ប្តូរការប្រឡង PSSA ថ្មី ដែលកាន់តែពិបាកនេះ ជាឧបសគ្គរារាំងដល់ឱកាសរបស់សិស្សានុសិស្ស។

៤. នៅពេលដែលមានការបារម្ភអំពីលទ្ធផលប្រឡង PSSA ដែលអាចប៉ះពាល់ដល់សមត្ថភាពនៃការបង្រៀនរបស់គ្រូ គ្រូនឹងគ្មានការប៉ះពាល់អ្វីទេ។ ការវាយតម្លៃការរីកចម្រើននៅក្នុងប្រព័ន្ធវាយតម្លៃរបស់រដ្ឋ គឺពិនិត្យមើលការរីកចម្រើនរបស់សិស្ស ដោយប្រៀបធៀបទៅនឹងសិស្សានុសិស្សទូទាំងរដ្ឋ ហើយលទ្ធផលរបស់យើងគឺជាកញ្ចក់ឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរទូទាំងរដ្ឋ។

បើមើលត្រង់ចំណុចល្អ ទោះជាមានការប្រឡងដែលពិបាក ហើយខុសប្លែកក៏ដោយ ក៏សិស្សានុសិស្សជិត ៦.០០០ នាក់ ដែលរៀនថ្នាក់ទី ៣ ដល់ថ្នាក់ទី៨ កើនពិន្ទុពីកម្រិតទាបបំផុត (ក្រោមមូលដ្ឋាន - below basic) ទៅកម្រិតជិតខ្ពស់បំផុត (មូលដ្ឋាន - basic) ក្នុងការប្រឡងអក្សរសិល្ប៍អង់គ្លេស។

លទ្ធផលនៃការប្រឡង ឃីស្តូន (Keystone) ផ្នែកអក្សរសិល្ប៍របស់យើង សម្រាប់ឆ្នាំ ២០១៤-១៥ ក៏គួរឲ្យមានការអបអរសាទរផងដែរ។ (ការប្រឡង ឃីស្តូន ត្រូវបានគេរៀបចំឲ្យស្របទៅតាមមូលដ្ឋាននៃកម្មវិធីសិក្សារបស់រដ្ឋផិនស៊ីលវេញ៉ា (PA Core Standards) ដែលពិបាករួចទៅហើយ ដូច្នេះការប្រៀបធៀបពីមួយឆ្នាំទៅមួយឆ្នាំ អាចមានសុពលភាព។) ចំនួនសិស្សដែលបានពិន្ទុ ស្ទាត់ជំនាញ (proficiency) ផ្នែកអក្សរសិល្ប៍ ក្នុងចំណោមអ្នកប្រឡងលើកទីមួយ បានកើនឡើង ៧ ភាគរយ បើប្រៀបធៀបកាលពីឆ្នាំមុន និង ជាងបីភាគបួន នៃសិស្សវិទ្យាល័យរបស់យើង ឃើញមានការកើនក្នុងកម្រិតស្ទាត់ជំនាញផ្នែកអក្សរសិល្ប៍ លើសពីឆ្នាំមុន។

ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា (PDE) នឹងបង្ហាញលទ្ធផលនៃការប្រឡង PSSA និង ឃីស្តូន ចុងក្រោយបង្អស់របស់យើង នៅខែក្រោយ។ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា នឹងផ្ញើរបាយការណ៍របស់សិស្សម្នាក់ៗទៅសាលា នៅពាក់កណ្តាលខែកញ្ញា ហើយគេនឹងបញ្ជូនបន្តទៅផ្ទះ ជូន មាតាបិតា និង អាណាព្យាបាល។ ក្នុងពេលជាមួយគ្នានេះ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា បានរៀបចំការណែនាំដែលមានប្រយោជន៍ដល់ ក្រុមគ្រួសារ សិស្សានុសិស្ស និងអ្នកអប់រំ អំពីការប្រឡង PSSAs ថ្មី ព្រមទាំងលទ្ធផល (មាននៅក្នុងវិបសៃ http://www.education.pa.gov/Pages/PSSA-Information.aspx#.VcOymhNViko) ដែលយើងខ្ញុំនឹងផ្សព្វផ្សាយនៅក្នុងវិបសៃរបស់យើង ហើយនឹងមានបកប្រែទៅជាភាសាផ្សេងៗ។

យើងទទួលយកតាមមូលដ្ឋាននៃកម្មវិធីសិក្សារបស់រដ្ឋផិនស៊ីលវេញ៉ា (PA Core Standards) ដោយសារកម្មវិធីនេះបង្ហាញពី ចំណេះដឹង និងការប៉ិនប្រសប់ដែលសិស្សត្រូវការ ដើម្បីត្រៀមខ្លួនជាស្រេចសម្រាប់ មហាវិទ្យាល័យ និង អាជីព។ យើងខ្ញុំនឹងបន្តការស្វែងរកប្រាក់ជំនួយដែលយើងត្រូវការ ដើម្បីធ្វើយ៉ាងណាឲ្យសិស្សានុសិស្សរបស់យើងទាំងអស់ត្រៀមខ្លួនដើម្បីឲ្យត្រូវតាមសេចក្តីប្រាថ្នារបស់ មហាវិទ្យាល័យ និងនិយោជក នាពេលបច្ចុប្បន្ន។

សូមអរគុណចំពោះការគាំទ្រជាបន្តរបស់លោកអ្នក ដល់សិស្សានុសិស្ស និងសាលា របស់យើង។

ដោយសេចក្តីស្មោះស្ម័គ្រ



William R. Hite, Jr., Ed.D.

**ចំណុចសំខាន់ៗប្រាំ ដែលមាតាបិតាគួរដឹងអំពីការប្រឡង PSSA ថ្មី**

១. កាលពីនិទាឃរដូវកន្លងទៅនេះ គេបានផ្តល់ការប្រឡង PSSA ថ្មី នៅក្នុងថ្នាក់រៀនទូទាំងរដ្ឋផិនស៊ីលវេញ៉ា ពីថ្នាក់ទី៣ ដល់ ថ្នាក់ទី៨ សម្រាប់មុខវិទ្យាអក្សរសិល្ប៍អង់គ្លេស និងគណិតវិទ្យា។ ការវាយតម្លៃនេះ គឺជាការប្រឡង PSSA លើកទីមួយ ដែលត្រូវធ្វើឲ្យស្របតាម មូលដ្ឋាននៃកម្មវិធីសិក្សារបស់រដ្ឋផិនស៊ីលវេញ៉ា (PA Core Standards) ដែលពិបាកជាងពីមុន ដែលក្រុមប្រឹក្សាផ្នែកអប់រំរបស់រដ្ឋបានអនុម័តកាលពីខែកញ្ញានៃឆ្នាំ២០១៣។ មូលដ្ឋាននៃកម្មវិធីសិក្សាថ្មី គឺជាគោលបំណងដើម្បីឲ្យសិស្សរបស់រដ្ឋផិនស៊ីលវេញ៉ាត្រៀមខ្លួនជាស្រេច ជាពិសេសសម្រាប់ មហាវិទ្យាល័យ និង អាជីព ក្រោយពេលពួកគេបញ្ចប់ការសិក្សាពីវិទ្យាល័យ។

២. ការធ្លាក់ចុះកម្រិតលទ្ធផលនៃការប្រឡងរបស់សិស្ស មិនមែនជាការបង្ហាញថាពួកគេមិនខិតខំសិក្សានោះទេ។ ការផ្លាស់ប្តូរត្រូវការពេលវេលា រួមទាំងការអភិវឌ្ឍន៍នៃកម្មវិធីសិក្សា និង ការផ្តល់ជំនួយ ហើយឆ្នាំសិក្សា ២០១៤-២០១៥ គឺជាឆ្នាំទីមួយនៃការវាយតម្លៃថ្មីនេះ។ ការប្រៀបធៀបពិន្ទុនៃការវាយតម្លៃថ្មី  ទៅនឹងពិន្ទុនៃការវាយតម្លៃកាលពីមុន របស់សិស្ស មិនអាចមានប្រយោជន៍អ្វីទេ ដោយសារការវាយតម្លៃទាំងនេះស្របទៅនឹងកម្មវិធីសិក្សាខុសៗគ្នា។ លទ្ធផលនៃការប្រឡងឆ្នាំ២០១៥ គឺគ្រាន់តែជាការកត់ចំណាំទុកនៅក្នុងពេលបច្ចុប្បន្ន ហើយអាចយកធ្វើជាខ្នាតគំរូសម្រាប់ការរីកចម្រើននៃការសិក្សានាពេលអនាគត។

៣. វិធីនៃការអភិវឌ្ឍន៍កម្មវិធីសិក្សាថ្មី និងកម្រិតនៃពិន្ទុ បានធ្វើឡើងដោយហ្មត់ចត់ និងគិតគូរយ៉ាងច្បាស់លាស់ ដោយគណកម្មាធិការអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា។ នៅពេលដែលសិស្សានុសិស្ស និងគ្រូ ដឹងកាន់តែច្បាស់កម្មវិធីសិក្សាថ្មី ហើយកាន់តែមានជំនួយសម្រាប់ការផ្លាស់ប្តូរសម្រាប់កម្មវិធីសិក្សាថ្មីនេះ នឹងធ្វើឲ្យសិស្សានុសិស្សមានការរីកចម្រើនក្នុងការសិក្សាជានិរន្តរ៍។

៤. លទ្ធផលនៃការប្រឡងទូទៅ មិនមែនជាការបញ្ជាក់តែមួយគត់ អំពីជោគជ័យរបស់សិស្សនោះទេ។ សិស្សានុសិស្សមានចំណុចពូកែខុសៗគ្នា និងមានការរីកចម្រើនតាមវិធីផ្សេងៗគ្នា។ វាជាការសំខាន់ដែលត្រូវវាយតម្លៃសិស្សានុសិស្សគ្រប់លក្ខណៈទាំងអស់ ដោយប្រើការវាយតម្លៃលើចំណេះដឹងតាមវិធីផ្សេងៗ។

៥. លោកអ្នកអាចជួយកូនឲ្យមានការរីកចម្រើនក្នុងការសិក្សា ដោយពិនិត្យមើលលទ្ធផលនៃការប្រឡង PSSA របស់កូន ជាមួយពួកគេ និងតាមការជួយជំរុញឲ្យពួកគេខិតខំសិក្សាឲ្យអស់ពីសមត្ថភាពនៅសាលា ជាបន្ត។

## នៅពេលដែលលោកអ្នកទទួលពិន្ទុនៃការប្រឡង៖ ពិគ្រោះជាមួយកូនលោកអ្នក

កាលពីនិទាឃរដូវកន្លងទៅនេះ គេបានផ្តល់ការប្រឡង PSSA ថ្មី នៅក្នុងថ្នាក់រៀនទូទាំងរដ្ឋផិនស៊ីលវេញ៉ា ពីថ្នាក់ទី៣ ដល់ ថ្នាក់ទី៨ សម្រាប់មុខវិទ្យា អក្សរសិល្ប៍អង់គ្លេស និងគណិតវិទ្យា។ ការវាយតម្លៃនេះ គឺជាការប្រឡង PSSA លើកទីមួយ ដែលត្រូវធ្វើឲ្យស្របតាម មូលដ្ឋាននៃកម្មវិធីសិក្សារបស់រដ្ឋផិនស៊ីលវេញ៉ា (PA Core Standards) ដែលពិបាកជាងពីមុន ដែលក្រុមប្រឹក្សាផ្នែកអប់រំរបស់រដ្ឋបានអនុម័តកាលពីខែកញ្ញានៃឆ្នាំ២០១៣។

មូលដ្ឋាននៃកម្មវិធីសិក្សាថ្មី គឺជាគោលបំណងដើម្បីឲ្យសិស្សរបស់រដ្ឋផិនស៊ីលវេញ៉ាត្រៀមខ្លួនជាស្រេច ជាពិសេសសម្រាប់ មហាវិទ្យាល័យ និងអាជីព ក្រោយពេលពួកគេបញ្ចប់ការសិក្សាពីវិទ្យាល័យ។ គឺជាការសំខាន់ណាស់ ដែលលោកអ្នកត្រូវរំឭក និងពន្យល់កូនរបស់លោកអ្នកថា ការផ្លាស់ប្តូរទៅមូលដ្ឋាននៃកម្មវិធីសិក្សាថ្មី ដែលកាន់តែលំបាកនេះ គឺត្រូវការពេលវេលា។ លទ្ធផលឆ្នាំនេះគឺទុកជាមូលដ្ឋានដើម្បីវាយតម្លៃការរីកចម្រើននៅថ្ងៃមុខ ហើយសមត្ថភាពរបស់កូនលោកអ្នកនឹងរីកចម្រើនឡើង នៅពេលដែលពួកគេកាន់តែយល់ច្បាស់អំពីមូលដ្ឋាននៃកម្មវិធីសិក្សាថ្មីនេះ។

វាក៏ជាការសំខាន់ដែរ ក្នុងការជួយកូនលោកអ្នកឲ្យយល់អំពីលទ្ធផលនៃការប្រឡងរបស់ពួកគេ – ទាំងចំណុចពូកែ និងចំណុចដែលត្រូវការកែលម្អ។

ចំណុចសំខាន់ៗមួយចំនួនដែលលោកអ្នកគប្បីបញ្ជាក់ជាមួយកូន នៅពេលដែលលោកអ្នកមើលពិន្ទុរបស់កូន ជុំគ្នា៖

- មូលដ្ឋាននៃការសិក្សាមានការផ្លាស់ប្តូរ។ មានតម្រូវការច្រើនជាងមុន និងគោលបំណងដែលគេចង់បាន ខ្ពស់ជាងមុន។
- ការប្រឡងមានការផ្លាស់ប្តូរ។ សំណួរក្នុងការប្រឡងបានរៀបចំឲ្យស្របតាមមូលដ្ឋាននៃការសិក្សា ហើយសំណួរជាច្រើន ពិបាកៗជាងឆ្នាំមុនៗ។
- មើលពិន្ទុនៃការប្រឡងជាមួយគ្នា។ សួរកូនលោកអ្នក ថាតើពួកគេមានអារម្មណ៍ដូចម្តេចអំពីការប្រឡងនេះ ហើយថាតើសំណួរទាំងនេះពិបាក ឬទេ។
- ពន្យល់កូនលោកអ្នក បើសិនជាពិន្ទុនៃការប្រឡងមិនបានខ្ពស់ដូចការរំពឹងទុក កុំឲ្យបាក់ទឹកចិត្ត។ សូមជ្រាបថា ការប្រឡងឆ្នាំនេះមានការពិបាកជាងមុន ហើយពេលវេលា និងការខិតខំជាបន្តរបស់លោកអ្នក នឹងធ្វើឲ្យពួកគេសម្រេចបានតាមការចង់បានថ្មីនេះ។
- លោកអ្នក និង គ្រូ អាចជួយកូនលោកអ្នកឲ្យគិតអំពីអ្វីៗដែលពួកគេនឹងត្រូវធ្វើដើម្បីទទួលបានជោគជ័យ នៅពេលដែលពួកគេនៅរៀន និងក្រោយពេលរៀនចប់ពីវិទ្យាល័យ។ សូមជ្រាបថា ការប្រឡងទាំងនេះអាចជួយសាលាឲ្យត្រៀមសិស្សានុសិស្សសម្រាប់ក្រោយពេលរៀនចប់ពីវិទ្យាល័យ។ ទោះជាពីរបីឆ្នាំ ឬច្រើនឆ្នាំជាងនេះទៀត ទើបសិស្សរៀនចប់ពីវិទ្យាល័យ ក៏ដោយ ក៏ការប្រឡងទាំងនេះអាចជួយឲ្យ សាលា និង គ្រូ ធ្វើយ៉ាងណាឲ្យពួកគេត្រៀមខ្លួនជាស្រេចសម្រាប់ទិសដៅដែលពួកគេបានជ្រើសរើស។
- ជំរុញឲ្យកូនរបស់លោកអ្នកខិតខំសិក្សាជាបន្ត ហើយសូមជម្រាបឲ្យគ្រូបានដឹងនៅពេលដែលពួកគេត្រូវការជំនួយ។